

# រាជានិយមខ្មែរ

**សេរីការ**

គេថាស្រុកខ្មែរ មានអ្នកដឹកនាំ ពន្លង់ ក្នុង អវិជ្ជា យក ក្បួនលក់ជាតិ ជា នាយកធម៌ ពាក់ងារ ជា អភិជន អហិរិក[1], ភ្លេច វណ្ណភាពខ្លួន ពី កំណើត ជា រាស្ត្រ, ប្រើ អំណាច ជា យុត្តិធម៌ ប្រើ វណ្ណះ ជា អាជ្ញា ស៊ក រូប ជា ព្រះ អួតខ្លួន ថា ជា អ្នកមានបុណ្យ នាំគ្នា អនុវត្ត ច្បាប់ តាម ចិត្តចង់បាន, ចាប់ អ្នកស្នេហាជាតិ និង អ្នកការពារសិទ្ធិមនុស្ស ដាក់ គុក ឥតមាន ការវិនិច្ឆ័យ, សម្លាប់ ខ្មែរអ្នកជា ចោទថា ជនក្បត់សន្តិ ភាព ព្រោះ ខ្លួន មាន យួន ជា អ្នកការពារ ជា បងធំ រស់ជា អ្នកធំ នៅ កម្ពុជា ពាក់ស័ក្តិ ជា មន្ត្រីជាតិខេមរា ដូរឈ្មោះ ជា ខ្មែរ សែនពិរោះ រួច ធ្វើ ជា អ្នកអាន់ជ្រី ពេញក្រសួង ទុកខ្លួនជា ពួកជើងកាប់ ប្លន់ បាន រដ្ឋខេមរា យកមកធ្វើ ជា កម្មសិទ្ធិ ហើយ ដឹកយួន រាប់លាននាក់ ចូល មករស់នៅពេញស្រុកខ្មែរ ធ្វើជា ម្ចាស់ បំណុល ៧ មករា ស៊ីការប្រាក់ សងមិនដាច់ ទាំងដើមទាំងការ ត្រូវ ប្តូរនឹង ទឹកដី ជា កតវេទិតា[2]។

សព្វថ្ងៃ ស្តេច ថ្មី បាក់អំនួត គ្មាន អាមាត្រ ជា អ្នកទាស យក ព្រះសង្ឃ ជា អ្នកជំនួសអោយលុតជង្គង់ សំពះ អញ ជា ស្តេច វង្វេងជាតិ ព្រោះ គ្មានចំណេះ ជាមហារាជ្យ មាន ទសពិធរាជធម៌ យក ពុទ្ធសាសនា ជា ធម៌ យក យុត្តិធម៌ ជាក្បួន ស្វែងរក សុខដុម សំរាប់ សង្គមជាតិ។ ស្តេច សីហមុនី ឈ្មោះនេះ មានន័យល្អ សមជា ក្សត្រ មាន ការចេះដឹងមាន បារមី ជា សមណៈ ដើរស្វែង រកធម៌ ដើម្បី បំរើប្រជារាស្ត្រ ព្រោះជារាស្ត្រ ទ្រទ្រង់ព្រះអង្គ ហើយ ទុកជាឧត្តមជន មានគតិយុត្តិធម៌ ក្នុងប្រាជ្ញា ប្រកបដោយ សេចក្តីស្នេហា ដែលជា ជម្រក ដ៏ត្រជាក់ត្រជុំ ដល់ ជាតិខេ មរា។ តែការពិត ឈ្មោះ និង អាកប្បកិរិយា របស់ព្រះអង្គ មានខ្លឹមសារ ខុសគ្នា ព្រោះ ឈ្មោះ សីហមុនី ជា តោយួន គេចិញ្ចឹមក្នុងសួនសត្វ ហៅ ថាវាំង មាន របបចំណី គឺ សាច់កូនខ្មែរ និង ឈាមជាតិខេមរា ជាទឹក ផឹក រស់គ្មានដឹងការពិតពីទុក្ខខ្មែរ, គិតតែងតាំងងារ ពួកលួចជាតិជា សម្តេច ហើយមាន អ្នកបន្ទរ ថាត្រូវគោរព ព្រោះជាងារ រាជអំណោយ

[1]អហិរិក ; sans pudeur, ignoble។

[2]កតវេទិតា ; remerciement sans fin។

ជាមហាកិត្តិយស សំរាប់រាស្ត្រ ទោះបីជាតិកំពុងមានអន្តរាយ ដោយសារ មានយួនរស់ពេញស្រុក ; ត្រូវនាំគ្នា ប្រើ រាជងារ ក្នុងចុតហ្មាយ ដើម្បី ជា ប្រណិប័តន៍ ដល់បូជនីយៈ (homme respectable) ព្រោះពួកសម្តេច ជា អ្នកដឹងគុណដល់យួន ស្រប៉ាំង[3] នឹង គុណមាតា។

ស្តេចខ្មែរណា មានអគតិ គឺជាស្តេច មិនស្គាល់ព្រះពុទ្ធ ព្រះធម៌ព្រះសង្ឃ ជា ព្រះរតនត្រ័យ ដែលប្រសើរ ក្រៃលែងជាង អវិញ្ញាណករតនៈ និង សវិញ្ញាណករតនៈ មានមាសជាដើមក្តី មានស្រីកែវជាដើមក្តី ប្រៀបផ្ទឹម នឹង ព្រះរតនត្រ័យមិនបានទេ ដូចយ៉ាង មាសប្រាក់ បើគេយកទៅ ប្រដាប់លើមនុស្សទុច្ចរិត វាមិនអាចធ្វើគេ ឲក្លាយទៅជាមនុស្សល្អ គួរ គោរពបានឡើយ មិនប្លែកគ្នាពីគេយក មកុដ ទៅប្រដាប់ ឲស្វាប់ ប៉ុន្នានទេ[4]។ ការយកព្រះសង្ឃ ជា ទ្រនាប់ព្រះបាត លុតជង្គង់ ក្រាប ថ្វាយបង្គំអញ ជា ស្តេច គឺដូចគ្នានឹង ស្វា ប្រាដាប់មកុដ មិនស្គាល់ បុណ្យ-បាប ជា ជនខ្មែរ មិនដឹងប្រពៃណី ជា មហាក្សត្រខេមរា រស់ ទំនឹមនឹង មនុស្សពាល ឥតសាសនា។ គេសន្និដ្ឋានបានថា រាជានិយម មានស្តេច ឥតស្គាល់ ព្រះរតនត្រ័យ ជា រាជានិយមកាឡៃ នៅក្នុងរដ្ឋ មាន ពុទ្ធសាសនា ជាខ្សែសីមា សំរាប់ការពាររដ្ឋា មាន ព្រះសង្ឃនាំថា គ្រប់បីដង សំរាប់អ្នកសមាទានថាតាមៈ

ខ្ញុំព្រះករុណា សូមដល់ព្រះពុទ្ធ ជាទីពឹង ទីរឭក។ ខ្ញុំព្រះករុណា សូមដល់ នូវធម៌ ជាទីពឹង ទីរឭក។ ខ្ញុំព្រះករុណា សូមដល់ព្រះសង្ឃ ជាទីពឹង ទីរឭក។ ដូច្នេះ ព្រះរតនត្រ័យពិតជាទីពឹង ទីរឭក ជា កត្តូបការៈ និងពំនឹង នៃ ប្រជាជាតិ រាប់ពាន់ឆ្នាំ។ ចុះហេតុអ្វី ស្តេចសីហមុនី ព្រះអង្គប្រម ភ្លេច[5] ធាតុដើមកំណើតខ្លួន ជា វង្ស អ្នកទ្រទ្រង់ពុទ្ធសាសនា និង ពុទ្ធ សាសនិក ច្រើនសតវត្ស ឥតលំអៀង ក្នុងដែនសុវណ្ណភូមិ ? ចម្លើយ មាន តែមួយគត់ ព្រោះ ព្រះអង្គ ខ្លាច យួនកុម្មុយនិស្ត អ្នកប្រទូស សាសនា; ឪ! អនិច្ចា នេះហេតុតែ ព្រះអង្គ ជាលុទ្ធបុគ្គល ស្រឡាញ់បល្ល័ង ជាង ជាតិ និង សាសនា សុខចិត្ត ធ្វើស្វា ប្រដាប់មកុដ រស់ក្នុងសុភ មង្គលអាត្មា លើទុក្ខរាស្ត្រ, រស់ សំរាប់ជាតិស្លាប់ ព្រោះ ចង់ធ្វើស្តេចទាស

[3] ស្រប៉ាំង ; de même dimension។

[4] សូមអានសៀវភៅ រៀមរៀងដោយ ភិក្ខុ ងិន ភេង ឥន្ទប្បញ្ញោ ព្រះអង្គធ្វើការពន្យល់អំពីខ្លឹម សសារ នៃព្រះរតនត្រ័យ។

[5] ប្រមភ្លេច ; Presque oublié។

បំរើឃ្លួនយ៉ាងមោះមុត រហូតដល់ថ្ងៃស្លាប់ ភ្លេច ញាតិមិត្ត ជាអ្នកស្នេហាជាតិ ភ្លេចអស់ថាស្រុកខ្មែរ មានខ្មែរជាម្ចាស់ស្រុក។




ឪ! អនិច្ចា នេះហេតុតែ ព្រះអង្គ ក្បត់សាសនា